**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកៅស៊ូ**

ថ្ងៃ.ពុធ...៤រោច..ខែភទ្របទឆ្នាំខាល.ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី...១៤...ខែ...កញ្ញា...ឆ្នាំ២០២២

លេខ: ៧៤៣ អក.នន

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់**៖-របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២២.............ចំនួន០១ច្បាប់

-តារាងស្ថានភាពផលិតកម្មកៅស៊ូ តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួត និងតារាងបរិមាណផលិតផលឈើកៅស៊ូកែច្នៃ និងនាំចេញប្រចាំខែសីហា ឆ្នាំ២០២២...........................ចំនួន០៤ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តសម្រាប់ចុះក្នុងរបាយការណ៍របស់ក្រសួងក្នុងខែកញ្ញា ដោយសង្ខេបដូចខាងក្រោម៖

**១- ផ្ទៃដីកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៤ ០៤៤ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ៣១០ ១៩៣ហិកតា ស្មើនឹង៧៧% និងផ្ទៃដីថែទាំមានចំនួន ៩៣ ៨៥១ហិកតា ស្មើនឹង២៣%។

**២- ផលិតកម្មជ័រកៅស៊ូ និងឈើកៅស៊ូ**

- ផលិតផលជ័រកៅស៊ូក្នុងខែសីហា ឆ្នាំ២០២២ មានចំនួន៣២ ៥៣៦តោន បានកើនឡើងចំនួន២ ០៣៨តោន ស្មើនឹង៧% ធៀបនឹងខែមុន និងបានកើនឡើងចំនួន២ ០២៧តោន ស្មើនឹង៧%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន
- ផលិតផលជ័រកៅស៊ូរហូតដល់ខែសីហា ឆ្នាំ២០២២ មានចំនួន១៩៤ ៥២៩តោន បានថយចុះចំនួន ៥៣៧តោន ស្មើនឹង០,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន
- ផលិតផលឈើកៅស៊ូសម្រេចបានក្នុងខែសីហា ឆ្នាំ២០២២ មានចំនួន៣ ១២៧ម៣ មានការថយចុះចំនួន២៥៨ម៣ ស្មើនឹង៧% ធៀបនឹងខែមុន
- ផលិតផលឈើកៅស៊ូរហូតដល់ខែសីហា ឆ្នាំ២០២២ សម្រេចបានចំនួន២២ ៣៧៦ម៣។

**៣- ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងខែសីហា ឆ្នាំ២០២២ មានចំនួន៣២ ៤៥១តោន បានកើនឡើងចំនួន២ ៨២៦តោន ស្មើនឹង៩,៥៤% ធៀបនឹងខែមុន និងបានបានកើនឡើងចំនួន២ ០១១តោន ស្មើនឹង(៧%) ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន
- បរិមាណបញ្ចេញលក់ជ័រកៅស៊ូរហូតដល់ខែសីហា ឆ្នាំ២០២២ មានចំនួន១៩៤ ០១៤តោន បានកើនឡើងចំនួន១ ៤៥៣តោន ស្មើនឹង១% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន
- បរិមាណបញ្ចេញលក់ឈើកៅស៊ូសម្រេចបានក្នុងខែសីហា ឆ្នាំ២០២២ មានចំនួន៣ ១០០ម៣ មានការកើនឡើងចំនួន១៩៨ម៣ ស្មើនឹង៦%ធៀបនឹងខែមុន
- បរិមាណបញ្ចេញលក់ឈើកៅស៊ូរហូតដល់ខែសីហា ឆ្នាំ២០២២ សម្រេចបានចំនួន២០ ៦២៩ម៣។

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No. 6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥)៩៥ ៣៨៨ ៨៦៨
Phone: (855) 95 388 868, Email: gdr.maff@gmail.com